# ការសំភាសន៍របស់ម៉ាក់ ហែម ស៊ីម

កៈ អ្នកធ្វើការសំភាសន៍ដោយ គីម ម៉េង     ខៈ អ្នកដែលត្រូវបានគេសំភាសន៍ហែម ស៊ីម

កៈ
ចឹងជាដំបូងជំរាសួរអ្នកម៉ាក់ខ្ញុំបាទបានមកពីរខាងសាកលវិទ្យាល័យបីបាយយូនៃសហរដ្ឋអាមេរិចហើយមានការអញ្ជើញដើម្បីមានការសំភាសន៍អ្នកម៉ាក់អំពីពង្សប្រវត្តិតតើអ្នកម៉ាក់អោយអនុញ្ញាត្តិអោយសំភាសន៍លោកយាយពង្សប្រវត្តិអ្នកម៉ាក់បានដែលទេ៕

ខៈ ចាសបាន៕

កៈ
ចឹងថ្ងៃនេះគឺជាថ្ងៃដែលខ្ញុំបានសំភាសន៍អ្នកម៉ាក់គឺជាថ្ងៃទី០៩ខែមីនាឆ្នាំ២០១៨ហើយធ្វើការសំភាសន៍ដោយរូបខ្ញុំបាទឈ្មោះគីមម៉េងហើយនាក់សំភាសន៍អ្នកម៉ាក់ហែម ស៊ីម
ចឹងផ្តើមឈ្មោះដំបូងខ្ញុំអាចស្គាល់ឈ្មោះរបស់អ្នកម៉ាក់៕

ខៈ ចាសបានខ្ញុំឈ្មោះហែម ស៊ីម៕

កៈ ហើយឈ្មោះហៅក្រៅមានឈ្មោះអ្វីដែល៕

ខៈ ឈ្មោះហៅក្រៅហែម ស៊ីម៕

កៈ ចឹងនៅក្នុងឆ្នាំនឹងតើអ្នកម៉ាក់មានព្រះជន្មប៉ុន្មានដែលហើយម៉ាក់៕

ខៈ ចាសនៅក្នុងឆ្នាំនឹងខ្ញុំមានអាយុចំនួនហាសិបប្រាំបួនឆ្នាំហើយ៕

កៈ
ចឹងនៅក្នុងឆ្នាំនឹងអ្នកម៉ាក់មានព្រះជន្មចំនួនហាសិបប្រាំបួនឆ្នាំហើយហើយម៉ាក់មានទីកន្លែងកំណើតនៅទីណាដែលម៉ាក់?៕

ខៈ ចាសខ្ញុំមានទីកន្លែងកំណើតនៅគីឡូម៉ែត្រលេខប្រាំមួយ៕

កៈ ហើយម៉ាក់មានទីកន្លែងកំណើតនៅភូមិអ្វីស្រុកអ្វីដែលម៉ាក់?៕

ខៈ ចាសស្រុកកំណើតនៅគីឡូម៉ែត្រលេខប្រាំមួយភូមិហាហាមិនដឹងជានៅភូមិអីផងមើលតាមអត្តញ្ញាប័ត្រទៅភូមិឬស្សីកែវគីឡូម៉ែត្រលេខប្រាំមួយ៕

ក៖ បាទហើយអ្នកម៉ាក់បានកើតនៅមន្ទីពេទ្យរឺក៏នៅផ្ទះដែល?៕

ខ៖  ចាសគឺខ្ញុំបានកើតនៅមន្ទីពេទ្យ៕

ក៖ បាទមន្ទីពេទ្យនឹងមានឈ្មោះអ្វីដែល?៕

ខ៖  ចាសជំនាន់នឹងបានភ្លេចហើយដឹងតែថាគឺនៅមន្ទីពេទ្យគីឡូម៉ែត្រលេខប្រាំមួយ៕

ក៖
គឺកើតនៅមន្ទីពេទ្យគីឡូម៉ែត្រលេខប្រាំមួយនឹងតែម្ដងមែនទេម៉ាក់?៕ខ%ចាស៕ហើយម៉ាក់គឺជាកូនទីប៉ុន្មានដែលម៉ាក់?៕

ខ៖  ចាសខ្ញុំគឺជាកូនទី២៕

ក៖  គឺជាកូនទី២ចឹងតើម៉ាក់មានបងប្អូនចំនួនប៉ុន្មាននាក់ដែលម៉ាក់?៕

ខ៖ ចាសខ្ញុំមានបងប្អូនចំនួនប្រាំមួយនាក់៕

ក៖
បាទចឹងម៉ាក់មានមានបងប្អូនចំនួនប្រាំមួយនាក់ហើយពួកគាត់ទាំងអស់មានឈ្មោះអីគេដែលម៉ាក់?៕

ខ៖
ចាសទីមួយមានឈ្មោះហែមសឿងហើយទីពីរមានឈ្មោះហែមស៊ីមហើយទីបីមានឈ្មោះហែមសរុនហើយទីបួនមានឈ្មោះហែមសារីហើយទៅប្រាំមានឈ្មោះហែមសុខុមហើយនឹងទីប្រាំមួយមានឈ្មោះហែមវីលយ័៕

ក៖ ចឹងសរុបទាំងមានចំនួនប្រាំមួយនាក់អ្នកណោះម៉ាក់?៕

ខ៖  ចាសសរុបទាំងមានចំនួនប្រាំមួយនាក់អ្នក៕

ក៖
ហើយបងប្អូនរបស់ម៉ាក់សរុបទាំងមានចំនួនប្រាំមួយនាក់អ្នកនឹងមានស្រីចំនួនប៉ុន្មានហើប្រុសចំនួនប៉ុន្មានដែលម៉ាក់?ខ៖  ចាសគឺស្រីទាំងអស់គឺប្រាំមួយនាក់នឹងតែម្ដង៕

ក៖
បាទគឺស្រីទាំងអស់គឺប្រាំមួយនាក់នឹងតែម្ដងម៉ាក់ណោះចឹងបងប្អូនរបស់ម៉ាក់សរុបទាំងអស់មានចំនួនប្រាំមួយនាក់អ្នកនឹងគាត់របស់រានមានជីវិតទាំងអស់រីកយ៉ាងមិចដែលម៉ាក់?៕

ខ៖
ចាសបងប្អូនសរុបទាំងអស់នៅសល់តែប្រាំនាក់ទេគឺគាត់បានស្លាប់ម្នាក់នៅជំនាន់ពោលពត៕ក%ចឹងបងប្អូនសរុបទាំងអស់របស់ម៉ាក់នៅសល់តែប្រាំនាក់ទេមែនទេ?៕

ខ៖ ចាស៕

ក៖ បាទបងប្អូនរបស់ម៉ាក់ដែលស្លាប់នឹងតើគាត់មានឈ្មោះអីដែល?៕

ខ៖ ចាសគាត់មានឈ្មោះហៃម
សឿងហើយបានស្លាប់នៅជំនាន់ពោលពតដល់ពេលដែលចាំចាំទៅអត់បានឃើញគេក៏បានរត់ប្រាប់ថាយាយអើយយាយអើយកូនរបស់យាយឯងបានស្លាប់គឺពួពោលពតបានយកទៅវៃចោលហើយ៕

ក៖ បាទចឹងបងប្អូនដែលបានស្លាប់នឹងគាត់គឺជាកូនទីប៉ុន្មានដែលម៉ាក់?៕

ខ៖ ចាសអ្នកដែលបានពោលពតបានយកទៅសំលាប់គាត់គឺជាកូនទីមួយ៕

ក៖ ចឹងឪពុកម្ដាយរបស់ម៉ាក់ហើយពូកមានឈ្មោះអីគេដែល?៕

ខ៖
ចាសឪពុករបស់ខ្ញុំគាត់មានឈ្មោះហៃមប៊ុនហើយម្ដាយរបស់ខ្ញុំគាត់មានឈ្មោះគីមហេង៕

ក៖ បាទចឹងឪពុកម្ដាយរបស់ម៉ាក់ពួកគាត់មានអាយុប៉ុន្មានឆ្នាំហើយ?៕

ខ៖ ចាសពួកបានស្លាប់ហើយនឹង៕

ក៖ បាទនៅពេលដែលឪពុកម្ដាយរបស់ម៉ាក់គាត់ស្លាប់គាត់មានអយុប៉ុន្មានដែលហើយ?៕

ខ៖
ចាសនៅពេលដែលបានស្លាប់នឹងគឺគាត់មានអយុចំនួនជិតសិបមួយឆ្នាំហើយចាសម្ដាយគាត់ស្លាប់អាយុជិតសិបមួយឆ្នាំ៕

ក៖ ចុះឪពុក?៕

ចាសឪពុករបស់ខ្ញុំគាត់ឆ្នាំម្សាញ់ខ្ញុំមិនដឹងគាតអាយុប៉ុន្មានផងហាហាគាត់ចូលប្រហែលជាចូល៧០ជាងហើយចាសនឹងហើយគឺប្រហែលជាចូល៧០ជាងនឹងហើយ៕ហើយមានដឹងឪពុកម្ដាយរបស់ម៉ាក់គាត់កើតនៅឆ្នាំណាដែលរឺទេ?៕

ខ៖
ចាសអត់ដឹងផងនឹងហាសចាសប៉ុនតែបានត្រឹមដឹងថាគាត់មានអយុប្រហាក់ប្រហែលចូល៧០ជាងហើយនឹង៕

កៈ ចឹងឪពុកម្តាយរបស់ម៉ាក់គាត់កើតនៅភូមិអីស្រុកអីដែលទេ?៕

ខៈ ចាសស្រុករបស់ឪពុករបស់ខ្ញុំនៅល្វៀរអែមស្រុកល្វៀរសរនឹងនៅល្វៀរអែមយើងនឹង៕

កៈ បាទគាត់ស្រុកអីភូមិអីគេដែល?៕

ខៈ
ចាសមិនសូវស្គាល់ទេដឹលត្រឹមតែគាត់នៅស្រុកនៅល្វៀរអែមហើយម្តាយរបស់ខ្ញុំស្រុកកំណើតរបស់គាត់នៅខេត្តកំពង់ឆ្នាំងហើយគាត់នៅស្រុកអីភូមិអីគឺអត់ដឹងទេគ្រាន់ដឹងថាគាត់មានស្រុកកំណើតនៅខេត្តកំពង់ឆ្នាំងតែប៉ុននឹងចាស៕កៈ
បាទចឹងនៅក្នុងជនាន់នឹងតើឪពុកម្តាយរបស់ម៉ាក់តើពួកគាយ់បានផ្តល់ការសក្សាទោដល់ម៉ាក់ដែលរឺទេដែលនៅក្នុងជំនាន់នឹង?៕

ខៈ ចាសអត់ទេ៕

កៈ
តើនៅក្នុងជំនាន់នឹងតើផល់លំបាក់អ្វីខ្លះបានជាឪពុកម្តាយរបស់ម៉ាក់មិនបានផ្តល់ការសិក្សាដល់ម៉ាក់យ៉ាងដូចថ្នឹង?៕

ខៈ
ចាសគឺពួកគាត់និយាយទៅគឺពួកគាត់ក្រតែម្តងឪពុកគាត់ទៅស៊ីឈ្នួយបើកឡានអោយគេហើយម្តាយគាំត់លក់ដូរ៕កៈ
ចឹងដែលនៅក្នុងជំនាន់នឹងឪពុកម្តាយរបស់ម៉ាក់គាត់ក្រអត់មានលត្តភាពដើមប្បីផ្តល់ការសិក្សាទៅម៉ាក់នោះទេឪពុកគាត់ទៅស៊ីឈ្នួយបើកឡានអោយគេហើយម្តាយគាំត់លក់ដូរអត់មានពេលដើមប្បីអោយម៉ាក់ទៅរៀនទេមែនទៃ?៕

ខៈ ចាស៕

កៈ
ចឹងនៅក្នុងជំនាន់មួយនឹងណោពេលម៉ាក់អត់បានសិក្សាតើម៉ាក់បានទៅរៀបការជាមួយប្តីរបស់ម៉ាក់តើម៉ាក់រៀបការជាមួយគាត់ដោយចិត្តចង្ខំរឺក៏ដោយស្មាក់ចិត្ត?៕

ខៈ ចាសគឺដោយស្រលាញ់គ្នាគឺមិនការបង្ខំអីនោះទេ៕

កៈ តើម៉ាក់នៅពេលដែលស្រឡាញ់នឹងប្តីរបស់ម៉ាក់តើម៉ាក់បានរៀបការនឹងគ្នាដែលរឺទេ?៕

ខៈ ចាសគឺយើងស្រឡាញ់គ្នាគឺមិនបានរៀបការនោះទេ៕

កៈ ចឹងមូហេតុអ្វីបានជាម៉ាក់មិនរៀបការជាមួយនឹងប្តីរបស់ម៉ាក់យ៉ាងដូចថ្នឹង?៕

ខ៖
ចាសគឺនៅជំនាន់គឺយើងទាំងពីរនាក់គ្មានលុយហើយរស់ជាគ្នាហើយក៏មិនបានរៀបការជាមួយគ្នាទេគឺរស់នៅជាមួយគ្នាដោយមានកូនថៅតាមធម្មតាហើយយើងទាំងពីរស្រឡាញ់គ្នាហើយបានកូនហើយក៏បានបណ្តុំបណ្តាលអោយកូនថៅអីទៅរៀន៕

ក៖ ចឹងតើនៅក្នុងជំនាន់នឹងតើប៉ាគាត់បានប្រកបមុខរបបអ្វីដែលនៅក្នុងជំនាន់នឹង?៕

ខ៖  ចាសគាត់ធ្វើការបោះពុម្ពប្រត្តិទិនហើយខ្ញុំបានលក់ដូរអីតិចតួច៕

ក៖
ចឹងនៅពេលដែលម៉ាក់បានរៀបការជាមួយប្តីរបស់ម៉ាក់ហើយតើម៉ាក់មានកូនជាមួយប្តីរបស់ម៉ាក់ចំនួនប៉ុន្មាននាក់ដែល?៕

ខ៖  ចាសខ្ញុំមានកូនចំនួន២នាក់៕

ក៖ ហើយកូនរបស់ម៉ាក់ទាំង២នាក់នឹងគាត់មានឈ្មោះអីគេ?៕

ខ៖  ចាសកូនទី១មានឈ្មោះគីមគួងហើយកូនទី២មានឈ្មោះគីមម៉េង៕

ក៖
ចឹងកូនទី១មានឈ្មោះគីមគួងហើយកូនទី២មានឈ្មោះគីមម៉េងនៅក្នុងជំនាន់នឹងតើម៉ាក់ជួបនៅបង្ហាញពិបាក់អ្វីខ្លះដែលម៉ាក់?៕

ខ៖
ចាសគឺពិបាក់គឺអត់មាននាក់ជួយមើលកូនរួចហើយគ្មាននាក់ជួយកូនឈឺក៏ម្នាក់ឯងហើយទៅណាក៏ម្នាក់ឯងទៅមើលកោសខ្យល់ហើយកូនទៅអោយគ្រូមើលយកកូនទៅអោយលោកមើលហើយអោយលោកស្រោកទឹកហើយពីដើមគឺមានតែបិននឹងចាសតែល្វូវគឺមានពេទ្យសំបូរណាសមិនដូចពីដើមមិនមានពេទ្យសំដូវល្វូវនោះទេចេះតែតិចអីយកកូនទៅស្រោកទឹកយកទៅផ្ញើរលោកអោយលោកជួយមើល៕

ក៖
ចឹងនៅពេលដែលម៉ាក់បាននៅជាមួយប្តីរបស់ម៉ាក់ហើយនឹងជាមួយកូនទាំង២របស់ម៉ាក់ហើយតើជួបផល់លំបាក់អ្វីខ្លះដែលនៅក្នុងចង្កោមដែលនៅក្នុងគ្រួសាររបស់អ្នកម៉ាក់ដែលម៉ាក់?៕

ខ៖
ចាសពិបាក់ណាស់រាល់ថ្ងៃគ្មាននាក់ជួយប្តីក៏មិនបានជួយទៅណាក៏ទៅតែម្នាក់ឯងពីបាក់ណាស់តែមិនដឹងត្រូវធ្វើយ៉ាងមិចតរស៊ូចិញ្ចឹមកូនហើយប្តីគឺមិននៅជួយទៀតគឺគាត់ដឹងតែដល់ម៉ោងធ្វើការគឺទៅធ្វើការហើយយកលុយមកអោយមកមើលកូន៕

កៈ
បាទចឹងម៉ាក់នៅពេលដែលជំនាន់នឹងតើម៉ាក់ហើយនឹងប្តីរបស់ម៉ាក់ចូលចិត្តឈ្លោះគ្នារឺក៏មានសេចក្តីស្រឡាញ់នឹងគ្នាដែលម៉ាក់ដែលរឺយ៉ាងមិច?៕

ខៈ
ចាសគឺយើងមិនដែលឈ្លោះគ្នាទេគឺមានពេលនឹងយើងឈ្លោះម្តងគឺគាត់បានជេរម្តាយខ្ញុំម្តងហើយខ្ញុំក៏បានជេម្តាយគាត់វិញក៏ឈប់ទៅ៕

កៈ បាទចឹងសេចក្តីស្រឡាញ់របស់ម៉ាក់ហើយនឹងប្តីរបស់ម៉ាក់យ៉ាងដូចម្តេចដែលម៉ាក់?៕

ខៈ ចាសស្រឡាញ់គាត់តែមិនអោយគាត់ដឹងចិត្តនោះទេ៕

កៈ ចឹងម៉ាក់ស្រឡាញ់ដែលមិនអោយគាត់ដឹងចិត្តនឹងដឹងយ៉ាងមិចដែលម៉ាក់?៕

ខៈ
ចាសស្រឡាញ់គាត់មិនគាត់ដឹងយើងចេះតែយកចិត្តគាត់ទៅតែចេះតែយកចិត្តគឺពេលដែលគាត់បានមកពីធ្វើការវិញគឺខ្ញុំបានដាំបាយបោកខោអាវហើយនឹងរៀបចំបាយអោយគាត់ហូបទៅ៕

កៈ
បាទចឹងខ្ញុំចង់សួរទៅកាន់ម៉ាក់ថានៅក្នុងជំនាន់ដែលម៉ាក់ហើយនឹងប្តីរបស់ម៉ាក់ស្រឡាញ់គ្នាតើជំនាន់ពោលពតនឹងតើជំនាន់ពោលពតនឹងគេអោយម៉ាក់ធ្វើគេដែលខ្លះដែលម៉ាក់?៕

ខៈ
ចាសនៅពេលដែលគេជំលាសខ្ញុំពីភ្នំពេញទៅដល់ព្រៃកញ្ចៅចូលទៅក្នុងវត្តដាំបាយហូបដល់ពេលនឹងខ្ញុំបានឃើញចងមនុស្សទាំងខ្សែរទាំងខ្សែរទាំងខ្សែរហើយបាញ់ហើយដល់ពេលចឹងទៅនាំគ្នាម៉ែកូនរុនរទេះទៅទៀតហើយម៉ែបានស្រែចប្រាប់ថារត់កូនអើយរត់កូនអើយរត់៕

កៈ បាទចឹងម៉ាក់រត់ពីព្រៃកញ្ចៅទៅដល់ណាវិញដែល?៕

ខៈ
ចាសគឺខ្ញុំរត់ទៅដល់ព្រៃក្តាមដល់ពេលរត់ទៅដល់នឹងហើយក៏គ្រកន្ទេរសំរាក់ហើយគឺនៅតាមផ្លូវហើយដល់ពេលនឹងយើងរត់ទៀតហើយចុះធ្វើមិចបើលយើងចឹងចេះតែអុសរទេះហើយធ្វើមិចហើយគេមិចយើងក៏ចឹងដែលនឹង៕

កៈ
ចឹងនៅពេលដែលម៉ាក់បានអុសរទេះរហូតទៅដល់ពីព្រៃក្តាមគេជុំលាសម៉ាក់ពីកំពង់ធំទៅដល់ណាវិញដែល?៕

ខ៖
ចាសគឺយើងអុសរទេះនឹងគឺយើងមិនដឹងថាយើងនឹងអុសរទេះនឹងទៅទីណានោះទេចេះតែអុសទៅអុសដល់កន្លែងណាដេកនៅទីនឹងទៅហើយដល់យប់ឡើងម៉ែបានប្រើអោយខ្ញុំនឹងទៅដង់ទឹកហើយយប់ឡើងនៅពេលដែលដង់ទឹងនឹងគឺយើងមិនបានឃើញស្អីនោះទេរួចហើយព្រឹងឡើងម៉ែក៏បានប្រើអោយខ្ញុំនឹងទៅដង់ទឹងម្តងទៀតរួចហើយខ្ញុំក៏បានឃើញឆ្អឹងខ្មោចហើយដល់ពេលនឹងគឺខ្ញុំក្អួតលេងចេញហើយនឹងរួចហើយម៉ែបានប្រើអោយខ្ញុំនឹងទៅដង់ទឹកហើយយប់ឡើងនៅពេលដែលដង់ទឹងនឹងគឺយើងមិនបានឃើញស្អីនោះទេរួចហើយព្រឹងឡើងម៉ែក៏បានប្រើអោយខ្ញុំនឹងទៅដង់ទឹងម្តងទៀតរួចហើយខ្ញុំក៏បានឃើញឆ្អឹងខ្មោចហើយដល់ពេលនឹងគឺខ្ញុំក្អួតលេងចេញហើយហើយខ្ញុំភ័យនោះភ័យហើយខ្ញុំនឹងម្តាយខ្ញុំក៏អុសរទេះទៅទៀតហើយហើយក៏មិនបានដឹងថាយើងអុសទៅដល់ណាទៀតដែលហាស៕

ក៖
បាទចឹងនៅពេលដែលម៉ាក់បានអុសរទេះតាមផ្លូវត្រូវគេជួបហើយត្រូវដង់ទឹកហើយបានប្រទេះឃើញឆ្អឹងខ្មោចតាមផ្លូវតើម៉ាក់បានហើយនឹងបានជួបពួកពោលពតនៅតាមផ្លូវទៀតដែលរឺយ៉ាងមិចដែលម៉ាក់?៕

ខ៖
ចាសនៅពេលដែលខ្ញុំបានទៅមុខទៀតខ្ញុំចេះតែបានេជួបពួកពោលពតដែលនឹងហាសហើយបានឃើញពួកវាបានកាន់នៅកាំភ្លើងហើយពួកពោលពតនឹងមើលទៅវាគឺក្មេងគឺក្មេងប៉ុនតែចេះតែភ័យហើយក៏ចេះតែអុសរទេះទៅហាសពីព្រោះអីខ្ញុំនៅក្មេងហើយខ្ញុំអាយុប្រហែលជាដបប្រាំរឺក៏ដកប្រាំមួយអីនឹង៕

ក៖
បាទចឹងនៅពេលម៉ាក់បានអុសរទេះនឹងនៅតាមផ្លូវបានជួបប្រទេះឃើញពួកពោលពតតើពួកពោលពតបានធ្វើអ្វីខ្លះដាក់ម៉ាក់ដែលរឺទេ?៕

ខ៖
ចាសគឺពួកវាមិនបានធ្វើអ្វីដាក់យើងនោះទេហើយយើងចេះតែភ័យក៏ចេះតែអុសរទេះនឹងទៅរហូតទៅរហូតទៅរហូតហើយបានឃើញវាចេះតែភ័យហើយក៏ចេះតែទៅហើយពីព្រោះអីកាល់នឹងខ្ញុំនៅក្មេងនឹងហើយខ្ញុំអាយុប្រហែលជាដបប្រាំរឺក៏ដកប្រាំមួយអីនឹងភ្លេចអស់ហើយយូរហើយនឹង៕

ក៖
បាទចឹងពោលពតបានឃើញម៉ាក់នៅតាមផ្លូវបានជួបប្រទេះឃើញម៉ាក់អីនឹងពួកពោលពតមិនបានធ្វើបាបម៉ាក់ទេមែនទេ?៕

ខ៖
ចាសនៅពេលពួកពោលពតបានឃើញម៉ាក់នៅតាមផ្លូវបានជួបប្រទេះឃើញម៉ាក់អីនឹងពួក

ពោលពតមិនបានធ្វើបាបអីនោះទេហើយយ៉ាងទៀតនៅពេលដែលខ្ញុំបានអុសរទេះនឹងគឺខ្ញុំមិនបានអុសរទេះទៅតាមផ្លូវកំពង់ធំទៀតទេគឺអុសរទេះទៅតាមផ្លូវកំពង់ចាមវិញចាស៕

កៈ
បាទហើយនៅពេលដែលម៉ាក់បានទៅតាមផ្លូវកំពង់ចាមវិញជួបពួកពោលពតដែលជាខ្មែរក្រហមទៀតដែករីទេ?៕

ខៈ
ចាសគឺមិនបានជួបនឹងពួកពោលពតទៀតទេដោយសារខ្ញុំបានទៅតាមផ្លូវតាមស្ទួងស្ទួងហើយនឹងស្មាច់៕

កៈ
បាទចឹងនៅដែលទៅតាមផ្លូវនឹងចឹងម៉ាក់មិនបានជួបពួកពោលពតទៀតទេមែនទេម៉ាក់?៕

ខៈ
ចាសអត់ទេគឺនៅតែបានឃើញដំដែលនឹងប៉ុនតែនៅពេលដែលបានជួបពួកពោលពតគឺពួកវាមិនបានធ្វើអីយើងនោះទេហើយយើងក៏បានមិនធ្វើអីដាក់ពួកពោលពតវិញដែលហើយនៅពេលដែលយើងបានទៅដល់ផ្ទះពួកទុងណោញហើយក៏បានជួបប្រទេះអ្នកដែលចិត្តល្អដល់ពេលនឹងគេអោយខ្ញុំបានឡើងទៅលើភ្នំរួចហើយខ្ញុំក៏បានទៅតាមគេដែលហើយនៅលើភ្នំនឹងគឺមានសត្វដ៏កាចសាហាវគឺជាសត្វខ្លារួចហើយគេក៏បានប្រាប់ម្ដាយខ្ញុំថាយាយយាយយាយគេបានយកកូនយាយឯងទៅណានឹងហើយកូនយាយឯងនឹងគាត់នឹងនៅក្មេងណាស់ហើយម្ដាយរបស់ខ្ញុំគាត់ក៏បានតវ៉ារួចហើយគាត់គឺមិនអោយទៅនោះទេដល់ពេលចឹងគេក៏បានខ្ញុំនឹងបានត្រឡប់មកផ្ទះវិញរួចហើយខ្ញុំក៏ទៅមើលសត្វសេកហើយមើលសេករួចហើយពេល
នឹងខ្ញុំក៏ខ្លៀនពេកក៏កាច់ពោតមួយហើយពេលនឹងខ្ញុំបាននិយាយថាខ្ញុំហែវពេកហើយគេក៏បាននិយាយម៉េចហែងដកវាទាំងឬយ៉ាងដូចថ្មឹងហើយខ្ញុំក៏បាននិយាយមកពីខ្ញុំខ្លៀ
នពេកមិនដឹងធ្វើម៉េចហើយគេបាននិយាយបើលឯងដាច់ពោតយ៉ាងដូចថ្មឹងចឹងមានតែយកឯងនឹងទៅកសាងហើយខ្ញុំឡឺយ៉ាងដូចខ្ញុំក៏ភ័យហើយខ្ញុំក៏បានរត់ទៅរកម្ដាយខ្ញុំតែម្ដាយខ្ញុំគាត់មិនបាននៅទៀតពីព្រោះម្ដាយរបស់ខ្ញុំគាត់ទៅធ្វើការបាត់ហើយដល់ពេលដែលខ្ញុំមករកម្ដាយរបស់ខ្ញុំមិនបានឃើញខ្ញុំក៏បានសុំទៅហើយនៅពេលដែលខ្ញុំបានសុំគេក៏ទៅបាត់ទៅហើយនៅពេលដែលខ្ញុំរកម្ដាយមិនបានឃើញខ្ញុំហើយដល់ពេលថ្ងៃក្រោយមកក៏បានយកខ្ញុំទៅជីកដីមួយម៉ែត្រគីបបួនជ្រុងហើយមួយម៉ែត្រមួយម៉ែត្ររួចហើយមកវិញគេក៏បានអោយខ្ញុំទៅបេះត្រកួនហើយនឹងទៅរើសខ្យន់រួចហើយក៏បានទៅបេះស្លឹកអំពៅមកស្លរម្ជូររួចហើយអត់មានអីហូបទេគឺដើររើសហើយនឹងទៅបេះតែចឹងរួចហើយនៅពេលនឹងគឺរាចហើយចឹងទៅគឺគ្មានពេទ្យនោះទេហើយពេលនឹងក៏ខ្ញុំក៏បានទៅចាងយកសំបកអំពៅទឹកហើយបេះត្រូយបែកហើយនឹងសំបកត្របែកពីព្រោះអីនៅជំនាន់នឹងគឺគ្មានថ្នាំទេគឺមានតែបិននឹង៕

កៈ
បាទចឹងនៅពេលដែលម៉ាក់អត់មានពេទ្យគ្រាន់តែដើររើសហើយបេះត្រួយបែកហើយនឹងសំបកត្របែកយកមកធ្វើថ្នាំនឹងតើគ្រាន់តែបេះត្រួយបែកហើយនឹងសំបកត្របែកយកមកព្យាបាទតើវាព្យាបាទជាដែលទេម៉ាក់?៕

ខៈ ចាសគឺបានជាហើយនឹងធូរបន្តិចចាស៕

កៈ
ចឹងនៅពេលដែលម៉ាក់បានព្យាលបានធូហើយនៅពេលដែលម៉ាក់បានជាហើយតើគេបានជំលាសម៉ាក់ពីណាទៅដល់ទៀតដែលម៉ាក់?៕

ខៈ
ចាសដល់ពេលនឹងពួកមិត្តបានជូនទៅលើទូតហើយដល់ពេលនឹងទៅដល់ស្ទូងចុបស្នាច់តៃណិនហើយនៅពេលដែលទៅដល់ព្រំដៃ
នវៀតណាមហើយនឹងព្រំដែនខ្មែររួចហើយដល់ពេលនឹងខ្ញុំក៏បានរត់លេងហើយរត់ទៅវិញទៅមកហើយខ្ញុំក៏បានបន់ល្ហិហើយខ្ញុំក៏បានរត់ទៅប្រទេសវៀតណាមបានកុំអីខ្ញុំប្រាកដខជាស្លាប់បាត់ហើយ៕

កៈ
បាទចឹងនៅក្នុងជំនាន់នឹងត្រូវគេបានជំលាស់ទៅប្រទេសវៀតណាមហើយត្រូវបានរស់រានមានជីវិតត្រូវដែលទេម៉ាក់?៕

ខៈ  ចាស៕

កៈ
បាទចឹងនៅពេលដែលម៉ាក់បានទៅរស់នៅប្រទេសវៀតណាមហើយនៅទីនឹងម៉ាក់បានេជួបផល់លំបាក់អីដែលខ្លះដែលម៉ាក់?៕

ខៈ
ចាសលំបាក់ណាស់គឺកគ្មានអីហូបទេគឺខ្ញុំបានចូលទៅព្រៃហើយនឹងដើររើសផ្លែឈើហូបពីព្រោះខ្ញុំបានគិតថាមានចាបហូបបានខ្ញុំក៏អាចហូបបានដែលហើយពេលនឹងគឺខ្ញុំមានជំទ្បូងហើយនឹងអង្គរបានមួយក្តាប់ហើយខ្ញុំក៏បានយកទៅដាំហើយអង្គរនឹងបានពុះព្លិចព្លិចរួចហើយក៏ដោសហូបទៅគឺគ្មានអីសំរាប់នឹងស៊ីនោះទេហើយនៅពេលដែលខ្ញុំបានរស់នៅប្រទេសវៀតណាមបានរយះពេលមួយឆ្នាំនៅក្នុងជំនាន់ឆ្នាំមួយពាន់ប្រាំបួនរយចិតសិបប្រាំបួនដល់ពេលនឹងខ្ញុំក៏បានឡឺដំណឹងថាឪពុករបស់ខ្ញុំគាត់នៅមានជីវិតចឹងទៅនៅពេលនឹងខ្ញុំក៏បានឡឺដំណឹងថាឪពុករបស់ខ្ញុំគាត់នៅមានជីវិតម្តាយរបស់ខ្ញុំម្តាយរបស់គាត់នៅប្រទេសវៀតណាមហើយឪពុករបស់ខ្ញុំគាត់នៅភ្នំពេញហើយពូររបស់ខ្ញុំក៏បានមកប្រាប់ម្តាយថាអើយមីងអើយមីងឪពុករបស់មីងគាត់នៅមានជីវិតទេហើយនៅពេកដែលយើងបានទទួលដំណឹងនឹ

ងហើយគាត់ក៏បានផ្ញើរលុយកាត់ខ្លះមកហើយគាត់បានអោយខ្ញុំនឹងបានត្រឡប់មកប្រទេសកម្ពុជាវិញរួចហើយដល់ពេលចឹងយើងក៏បានមកជួបជុំគ្នាហើយក៏បានអោបគ្នាហើយក៏បានយំហើយដល់ពេលចឹងដល់បានបួនប្រាំថ្ងៃដូចជាលេងរឿងយ៉ាងដូចថ្មឹងហើយក៏នាំគ្នាយំរួចហើយក៏ចាប់ផ្ដើមយកមាន់យកទារមកធ្វើពីធីជប់លៀងហូបជុំគ្នាចាសជីវិតរបស់ខ្ញុំគឺពិតជាពិបាក់ខ្លាំងណាស់ហើយនៅពេលដែលមកវិញក៏ពិបាក់ដែលហើយនៅពេលដែលខ្ញុំបានមកដល់ស្រុកវិញគឺជាប្រទេសកម្ពុជាគឺវាពិតជាពិបាក់ខ្លាំងណាស់គឺខ្ញុំគ្មានការងារនឹងធ្វើនោះទេហើយខ្ញុំក៏បានទៅច្បាអំពៅហើយខ្ញុំក៏បានចេះកង់ដុបហើយបានទិញអំពៅយកមកលក់គឺទាំងមានអំពៅសាងហើយនៅក្នុងជំនាន់នឹងគឺគ្មានអីនឹងលក់នោះទេចាសគឺពីបាក់ណាស់គឺយើងបានទៅទិញអំពៅហើយនឹងម្នាក់ហើយយកវាមកលក់ហើយយើងក៏បានអង្ករមួយគីឡូរអង្ករមួយគីឡូរបានរស់រាល់ថ្ងៃហើយកល់នឹងគឺខ្ញុំពិតជាពីបាក់ខ្លាំងណាស់ទៅដល់ស្រុកយួនគឺជាប្រទេសវៀតណាមគឺខ្ញុំពិតជាពីបាក់ខ្លាំងណាស់កាល់នឹងគឺខ្ញុំនៅក្មេងណាស់កាល់នឹងខ្ញុំទំតែមានអាយុប្រហែលជា១៥រឺ១៦តែបិននឹងហើយគេក៏បានអោយខ្ញុំនឹងទៅអូសត្រីរហូតដល់ម៉ោង១រឺក៏ដល់ម៉ោង២យប់ងនោះហើយណាមួយខ្ញុំក៏មិនសូវចេះហែរទឹងផងនឹងរួចហើយគេក៏បានអោយជាអង្ករប្រហែលជា២រឺក៏បាន៣កុំប៉ុងហើយនៅពេលដែលបានអង្ករប្រហែលជា២រឺក៏បាន៣កុំប៉ុងខ្ញុំក៏យកមកដាំបាយអោយបងប្អូនរបស់ខ្ញុំបានហូបរួចហើយដល់ពេលចឹងទៅក៏បានទៅរើសខ្យល់ហើយដើររើសខ្ទៅហើយនឹងដើររើសត្រកួនហើយយកខ្យល់ហើយហើយយកខ្ទៅហើយយកត្រកួនយកទៅលក់ហ៊ុមជីវិតតស៊ូរជីវិតពិបាក់កួនអើយហើយ៕

កៈ

ចឹងនៅពេលដែលម៉ាក់ទៅរកត្រីរកម្ហូបរកចំនីអាហារហើយនឹងទៅធ្វើការចឹងតើទៅនឹងមានបងប្អូនរឺក៏មានម្ដាយអីទៅជួយរកដែលរឺក៏យ៉ាងម៉េចដែលម៉ាក់?៕

ខៈ

ចាសគឺគ្មានទេគឺខ្ញុំបានដើររកតែម្នាក់ឯងហើយពិបាក់សឹងនឹងស្លាប់ទៅហើយហើយយ៉ាងខ្ញុំ២រឺក៏៣ថ្ងៃ២រឺក៏៣ថ្ងៃខ្ញុំទៅរកម្ដងហើយខ្ញុំនឹងក៏មិនសូវជាចេះហែរទឹកដែលហើយដល់ពេលនឹងគឺខ្ញុំនឹងហាត់ហើយមើលទៅកន្លែងណាដែលមានអីរាក់រាក់គឺខ្ញុំតោងតាមគេហើយចុះដឹងធ្វើយ៉ាងមិចបើលជាជិវិតរបស់ខ្ញុំវាពិបាក់ចឹងគឺមានតែអង្ករតែ៣កុំប៉ុនសំរាប់នឹងស៊ីតែបិននឹងរឺក៏មានតែ២កុំប៉ុងហើយនៅពេលព្រឹងព្រលឹងឡើងគឺខ្ញុំបានទៅទៀតហើយ៕

កៈ

ចឹងអរគុណច្រើនសំរាប់ម៉ាក់ចឹងសំរាប់ម៉ាក់សរុបសេចក្ដីសង្ខេបមកខ្ញុំក៏អត់សួរមានសំនួរអីច្រើនសំរាប់ម៉ាក់ដែលប៉ុនតែជាចុងក្រោយខ្ញុំគ្រាន់តែដឹងថាម៉ាក់ដែលនៅក្នុងជំនាន់ពោលពោម៉ាក់បានរត់ទៅខេត្តកំពង់ចាមហើយនឹងស្មាច់ហើយនឹងអីផ្សេងផ្សេងរហូតបានទៅដល់ប្រទេសវៀតណាមទើបម៉ាក់រស់រានមានជីវិតរហូតមកដល់សព្វថ្ងៃនឹងចឹងខ្ញុំចង់សួរម៉ាក់ថាតើម៉ាក់សព្វថ្ងៃនឹងតើម៉ាក់មានទីលំនៅន្លែងណាដែលសព្វថ្ងៃនឹងដែលម៉ាក់?៕

ខ៖
ចាសសព្វថ្ងៃនឹងទីលំនៅបច្ចុប្បន្នរសប់ខ្ញុំគឺខ្ញុំរស់នៅស្រុកថ្មរគោលសង្កាត់ឫស្សីកែវនឹងគីឡូម៉ែត្រលេខប្រាំមួយចាស៕

ក៖ ចឹងសព្វថ្ងៃនឹងតើម៉ាក់ប្រកបមុខរបបអ្វីដែលទៅម៉ាក់?៕

ខ៖ ចាសសព្វថ្ងៃនឹងខ្ញុំមិនបានប្រកបមុខរបបអ្វីទេគឺខ្ញុំមើលតែចៅនោះទេ៕

ក៖
ចឹងជាសំនួរចុងក្រោយរបស់ខ្ញុំខ្ញុំចង់សួរម៉ាក់ថាតើម៉ាក់មានអ្វីផ្ដែរផ្ដាំទៅដល់កូនចៅរបស់ម៉ាក់នៅពេលបច្ចុប្បន្នក៏ដូចជាកូនចៅជំនាន់ក្រោយដូចជាកូនចៅតួតកូនចៅលួតហើយមនឹងកូនចៅលាដែលនៅពេលដែលពួកបានឡឺសំលេងរបស់ម៉ាក់ហើយនឹងបានឡឺអំពីជីវិតកុំសត់របស់ម៉ាក់នៅពេលដែលជាជំនាន់ពោលពោតើម៉ាក់មានអ្វីផ្ដេរផ្ដាំទៅដល់ពួកដែលជាកូនចៅជំនាន់ក្រោយដែលរឺទេម៉ាក់?៕

ខ៖
ចាសជីវិតរបស់ខ្ញុំកាល់នៅជំនាន់ពោលពតគឺវាពិជាពិបាក់ខ្លាំងណាស់តែខ្ញុំគ្រាន់ផ្ដេរផ្ដាំទៅដល់កូនចៅថាម៉ែពិបាក់ខ្លាំងណាស់ដែលម៉ាក់នៅជំនាន់ពោលពតហើយយ៉ាងក្មេងសម័យអីលូវមើលទៅកូនឯងស្រួលណាស់តែបើលកូនឯងនៅជំនាន់ពោលពតវិញកូនឯងប្រែលជាស្លាប់បាត់ហើយហើយម្ដាយពិបាក់គ្រប់ស្រប់បែបយ៉ាងទាំងអស់ជីវិញរបស់ម្ដាយនឹងហោសហើយទាំងពីរស្អុងហើយពួកពោលពតពួកវាអោយខ្ញុំស្អុងហើយអាឃើញទឹកថ្លាថ្លាហើយនៅក្នុងគឺមានឈ្លូងហើយពួកឈ្លូងហើយវាទោងជើងហើយគឺវាពិបាក់ខ្លាំងណាស់បើលកូនឯងដែលនៅជំនាន់នឹងបានកូនឯងបានដឹងពីរជីវិតពិបាក់របស់ម្ដាយហើយម្ដាយតស៊ូខ្លាំងណាស់គឺជីវិតរបស់ម្ដាយគឺជាជីវិតពិបាក់ណាស់ហើយម្ដាយគ្រាន់តែចង់ប្រាប់កូនថាអោយមានភាពតស៊ូកុំអោយចុះចាញ់អីពីព្រោះជីវិតរបស់ម្ដាយគឺពិបាក់ខ្លាំងណាស់គ្រាន់តែចង់អោយកូនចេះតស៊ូដូចគេដូចឯងកូនអើយពីព្រោះជីវិតរបស់ម្ដាយគឺពិបាក់ខ្លាំងណាស់រាល់ថ្ងៃនឹងហើយយ៉ាងទៀតគឺម្ដាយយំលេងចេញហើយនៅពេលជំនាន់ពោលពតគឺម្ដាយដើរទៅបូតស្រូវហើយនឹងទៅយកកុំប៉ុងហើយនឹងដើររកឈើមកហើយនៅជំនាន់គឺគ្មានឈើសំរាប់នឹងបុកនោះទេហើយម្ដាយក៏បានយកស្រូវទាំងអស់នឹងមកបុកជាមួយនឹងកុំប៉ុនហើយទៅយកកុំប៉ុងហើយនឹងដើររកឈើមកហើយនៅជំនាន់គឺគ្មានឈើសំរាប់នឹងបុកនោះទេហើយម្ដាយក៏បានយកស្រូវទាំងអស់នឹងមកបុកជាមួយនឹងកុំប៉ុនហើយនឹងមានម្ជូកដែកកូវានឯងត្រូវតែតស៊ូពីព្រោះជីវិតរបស់ម្ដាយគឺវាពិតជាពីបាក់ខ្លាំងណាស់នៅពេលជំនាន់មុនម្ដាយចេះតែផ្ដេរផ្ដាំទៅដល់កូនចៅអើយអោយចេះតស៊ូឡើងហើយមួយទៀតត្រូវចេះព្រានប្រដៅកូនចៅឡើងអោយចេះតស៊ូឡើងពីព្រោះជីវិតរបស់ម្ដាយគឺវាពិតជាពិបាក់ខ្លាំងណាស់ជីវិតរបស់ម្ដាយនឹងហើយគឺម្ដាយបានដើរទៅបូតស្រូវហើយក៏បានយកម្ជូកដែកហើយនឹងកុំប៉ុងយកមកបុកហើយម្ដាយមិនចេះបុកទេគឺយកស្រូវទាំងអស់នឹងយកទៅអំឆាចឆាចឆាចវាឆាចចេះហើយម្ដាយមិនចេះអំគឺម្ដាយអង្គុយរើសគ្រាប់អង្ករពីព្រោះម្ដាយមិនចេះអំនោះទេហើ

យនៅជំនាន់គឺគ្មានចង្កេលអំគឺម្ដាយបានយកឆ្នាំងយកមកអំហើយម្ដាយអង្គុយរើសគឺម្ដាយ ម្ដាយអង្គុយរើសគ្រាប់អង្ករហើយម្ដាយមិនចេះរើសស្រូវផងនឹងរួចហើយរើសគ្រាប់ស្រូវបាន ហើយក៏យកទៀតហើយហើយម្ដាយក៏ចាប់ផ្ដើបអំទៀតហើយហើយទំរាំបានហើយម៉ែក៏យ កគ្រាប់ស្រូវដែលម៉ែបានអំនឹងគឺយកទៅដាំបបរគឺដាំបបរហើយលាយនឹងដំឡូងមីរួចហើយ ឈូសឈូសដំឡូងមីរួចហើយម៉ែយកទៅហាហើយហាដំឡូងមីរួចហើយអោយវាក្រៀបហើ យបានម៉ែយកទៅដាំលាយនឹងជាមួយនឹងបបរដាំបបរហើយដាក់ដំឡូងមីចូលហើយបន្ទាប់ ពីនឹងបបរក៏បានពុះប៉ុចប៉ុចហើយក៏ដោសម្នាក់បានមួយចានហើយគឺមិនហ៊ានអោយហួបឆ្អែ តនោះទេចង់កូនឯងត្រូវចេះតស៊ូឡើងពីព្រោះជីវិតរបស់ម្ដាយគឺវាពិតជាពិបាក់ខ្លាំងណាស់ ហើយតាំងពីស្លឹកបាស់ហើយនឹងតាំងពីដើមចេកគឺដុះមិនទាន់នោះទេគឺពេលព្រឹកកាប់ហើ យដល់ពេលល្ងាចម៉ែដើរមកមើលទៀតហើយហើយគឺយកមកនឹងគឺគ្មានអីនោះទេគឺយកម កស្ងោរឡើងពីព្រោះជីវិតរបស់ម្ដាយគឺវាពិតជាពិបាក់ខ្លាំងណាស់កូនអើយ៕

កៈ
បាទចឹងជាចុងក្រោយម៉ាក់គ្រាន់តែមានពាក្យផ្ដេរផ្ដាំផ្ញើទៅដល់កូនចៅរបស់ម៉ាក់ថាអោយកូ នចៅម៉ាក់ត្រូវចេះតស៊ូមិនថានៅជំនាន់នេះរហូតដល់ជំនាន់ក្រោយក្រោយទៀតរហូតដល់ ចៅតួចចៅលោតហើយនឹងចៅលារបស់ម៉ាក់អោយផ្ដាំផ្ញើរទៅកាន់កូនចៅរបស់ម៉ាក់នៅពេ លដែលពួកគាត់បានឡឺសំលេងរបស់ម៉ាក់ហើយសុំអោយពួកគាត់មានភាពតស៊ូឡើងហា ហើយកុំអោយចុះចាញ់ទោះបីមានឧបស័គយ៉ាងណាក៏ដោយចឹងនៅពេលដែលពួកគេបាន ឡឺសំលេងនឹងសឃ្សឹមថាពួកគាត់នឹងពុះពាល់នៅឧបស័គបានគ្រាប់យ៉ាងដោយសារនៅពេ លដែលពួកគាត់ដែលជួបនឹងឧបស័គនឹងគឺឧបស័គទាំងអស់នឹងគឺពុំស្មើឧបស័គរបស់ម្ដាយ ដែលម៉ាក់បានមាននៅក្នុងជំនាន់ពពោលពតគឺមិនស្មើនោះទេគឺធំធេងណាស់ដែលម៉ាក់បា នមាននៅជំនាន់ពោលពតនឹងនោះទេមែនដែលទេម៉ាក់?៕

ខៈ
ចាសគឺម្ដាយពិបាក់ខ្លាំងម្ដាយដើររកស្លឹកបាស់ហើយនឹងស្លឹងដំម៉ោយដំរីហើយនឹងវល្លហើ យនឹងឈ្មោអីទេភ្លេចបាត់ហើយហើយនឹងមានស្លឹកសាមម៉ៅហើយនឹងដំឡូងមីរហើយដំឡូ ងមីរនឹងធំធំហើយគឺបិនកុំភ្លៅចេសហើយគេអោយទៅគាស់គ្រោះរួចហើយត្រពាងក៏ស៊ីរួច ហើយត្រពាងក៏ស៊ីរួចហើយអីគេទៀតចេសហើយនឹងវល្លត្តិកហាហាហើយគឺខ្ញុំបានភ្លេចទាំ ងអស់ហើយលូវនឹងគឺខ្ញុំនឹងនឹកម្ដងបន្តិចនឹកម្ដងបន្តិចជីវិតរបស់ខ្ញុំគឺពិបាក់ខ្លាំងណាស់ហើ យផ្ដេរផ្ដាំមដល់កូនចៅរបស់ខ្ញុំតែបិននឹងចាស៕

កៈ
បាទចឹងខ្ញុំអត់មានទៀតទេដែលនៅក្នុងការសំភាសន៍ម៉ាក់ចឹងខ្ញុំក៏អត់មានអីច្រើនទៀតដែ លសំរាប់ការសំភាសន៍របស់ម៉ាក់ហើយចឹងខ្ញុំមានតែបិននឹងក្នុងចរចេកគ្នានឹងការសំភាសន៍ ម៉ាក់ផងដែលចឹងខ្ញុំហើយខ្ញុំមានតែបិននឹងហើយខ្ញុំនឹងបញ្ចប់ការសំភាសន៍របស់ខ្ញុំហើយនឹ ងម៉ាក់លូវនេះផងដែលចឹងអរគុណហើយណាម៉ាក់៕

ខ៖

ចាសហាហាឆ្ងាយណាស់គឺខ្ញុំមិនដែលបានហួបសព្វធ្លេនគឺខ្ញុំមិនដែលបានស៊ីធ្លេនហើយធ្លេននឹងគឺគ្មានសាច់នឹងស៊ីនោះទេហើយនៅពេលដែលបានឃើញធ្លេនវាលវៃហើយយកវាទៅស៊ីហើយវារស់ផ្អែមណាស់ហើយខ្ញុំបានប្រាប់គេគឺគ្មាននាក់ណាជឿរខ្ញុំនោះទេធ្លេនស៊ីទតាំងពីពស់ធ្លេនហើយនឹងពស់ព្រលឹតហើយនឹងអន្ទង់ហើយខ្ញុំចូលចិត្តធ្លេននឹងឆ្ងាញ់ណាស់តែបើលូវឃើញធ្លេនវាលខ្ញុំនឹងឃើញហើយធ្លេននឹងគឺវាផ្អែមមែនហើយបើលនៅជំនាន់នឹងគេយកសាច់គោយកប្តូរគឺគេមិនប្តូរផងហើយខ្ញុំឃើញវាវាលចេះតែនឹងឃើញហើយពីព្រោះអីខ្ញុំមិនដែលមានសាច់នឹងស៊ីផងនឹង៕

ក៖ ចឹងអរគុណច្រើនម៉ាក់ចឹងគឺខ្ញុំមានតែបិននឹងចឹងខ្ញុំសុំជំរាបលាម៉ាក់ម្តងទៀតណាម៉ាក់៕

ខ៖ ចាសអរគុណច្រើនដូចគ្នាណា៕

ក៖ បាទ!!!

ខ៖ ចាសអរគុណច្រើនសុំអោយមានក្តីសុខនឹងសុខសប្បាយណា៕